# សេចក្តីណែនាំ

## ស្តីពី

# ការគ្រប់គ្រង
# សំណល់គ្រោះថ្នាក់រោងចក្រ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៥៥៥៣❖៣៥៥៥៣

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

87 សជណ

រាជធានីភ្នំពេញ ថ្ងៃទី 26 ខែ ឧសភា ឆ្នាំ 2000

# សេចក្តីណែនាំ

## ស្តីពី ការគ្រប់គ្រងសំណល់គ្រោះថ្នាក់រោងចក្រ

<u>យោង:</u> - ព្រះរាជក្រមលេខ នស / រកម / ១២៩៦ / ៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ។ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

- អនុក្រឹត្យលេខ ២៧ អនក្រ / បក ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការត្រួតពិនិត្យការបំពុលទឹក ។
- អនុក្រឹត្យលេខ ៣៦ អនក្រ /បក ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការគ្រប់គ្រងសំណល់រឹង ។

ដោយពិនិត្យឃើញថា ការគ្រប់គ្រងសំណល់គ្រោះថ្នាក់នៅតាមរោងជាងជួសជុលគ្រឿងយន្ត ឬ រោងចក្រសហគ្រាសដែលមានលក្ខណៈមិនសមស្របទៅតាមបច្ចេកទេសដូចជា : សំណល់ប្រេងឥន្ធនៈ និងខ្លាញ់ សំណល់កកអាងស្តុក ឬ អាងប្រព្រឹត្តកម្ម និងសំណល់ចេញពីដំណើរការផលិតកម្ម ។ កន្លងមកនេះ មានការដឹកសំណល់គ្រោះថ្នាក់រោងចក្រយកទៅចាក់ចោលនៅតាមទីវាល និងតំបន់ទឹកសាធារណៈ ដែលជាហេតុបង្កអោយមានការបំពុលបរិស្ថាន និង ប៉ះពាល់ទៅ ដល់សុខភាពសាធារណៈ ។

ដើម្បីជំរុញការគ្រប់គ្រងសំណល់គ្រោះថ្នាក់នៅតាមរោងចក្រ សហគ្រាស និងរោងជាងជួសជុលគ្រឿងយន្ត អោយមានភាពល្អប្រសើរ សំដៅទប់ស្កាត់ការបំពុលបរិស្ថាន និង ការពារសុខ ភាពសាធារណៈ ក្រសួងបរិស្ថានសូមធ្វើការ ណែនាំដូចខាងក្រោម :

១. ត្រូវរៀបចំទុកដាក់សំណល់ប្រេងម៉ាស៊ីន និងសំណល់ប្រេងលាងក្នុងការជួសជុលគ្រឿងចក្រអោយបានសមស្រប និងជៀសវាងការបង្ហៀរ ឬចាក់ចូលទៅក្នុង បណ្តាញលូ ឬប្រភពទឹកសាធារណៈ ។

២. ត្រូវធ្វើការហាល ឬគៀបសំងួតសំណល់ភក់នៃអាងស្តុក និងអាងប្រព្រឹត្តកម្មសំអាត សំណល់រាវ ដែលបញ្ចេញពីខ្សែសង្វាក់ផលិតកម្ម និងធ្វើការស្តុកទុកបណ្តោះអាសន្ន អោយបានសមស្របនៅក្នុងទីតាំងរបស់ខ្លួន ជៀសវាងការប៉ះពាល់ដល់គុណភាព បរិស្ថាន និងសុខភាពសាធារណៈ ។

៣. ហាមដាច់ខាតការចាក់ចោល ឬដឹកសំណល់ភក់លាយឡំជាមួយសំណល់រឹងលំនៅស្ថាន ។

៤. ត្រូវធ្វើការសុំអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការដឹកជញ្ជូនសំណល់ភក់ស្ងួតចេញ ពីទីតាំងរោងចក្រ-សហគ្រាស ទៅកាន់ទីកន្លែងដទៃក្នុងគោលបំណងណាមួយ ។

៥. ត្រូវធ្វើការសុំអនុញ្ញាតពីក្រសួងបរិស្ថាន សំរាប់ការបញ្ចេញសំណល់រាវរោងចក្រចូល ទៅក្នុងលូ ឬតំបន់ទឹកសាធារណៈ ។

ទទួលបានសេចក្តីណែនាំនេះ ម្ចាស់រោងចក្រ រោងជាងជួសជុលគ្រឿងយន្តទាំង អស់ ត្រូវអនុវត្តការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ដែលបង្កើតនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយ សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ ។ ក្នុងករណីមិនអនុវត្តតាម ឬអនុវត្តផ្ទុយទៅនឹងសេចក្តីណែនាំ ខាងលើ ក្រសួងបរិស្ថាន និងចាត់វិធានការតាមផ្លូវច្បាប់ ។

រដ្ឋមន្ត្រី

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល
- សាលាខេត្ត-ក្រុង

"<u>ដើម្បីជូនជ្រាបជាព័ត៌មាន</u>"

- អគ្គនាយកដ្ឋាន
- នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន

"<u>ដើម្បីមុខការ</u>"

- មន្ទីរបរិស្ថានខេត្ត-ក្រុង "<u>ដើម្បីសហការតាមដានការអនុវត្ត</u>"
- ឯកសារ កាលប្បវត្តិ